## តើអ្វីជារោគរលាកថ្លើមប្រភេទ B?

រោគរលាកថ្លើមប្រភេទ B គឺជាការឆ្លងរោគថ្លើមធ្ងន់ធ្ងរ ដែលបណ្តាលមកពីវីរុសរលាកថ្លើមប្រភេទ B។ វាអាចជាជំងឺកម្រិតស្រាលរយៈពេលពីរបីសប្តាហ៍ ឬជំងឺធ្ងន់ធ្ងរអស់មួយជីវិត។

មនុស្ស 1 នាក់ក្នុងចំណោម 4 នាក់ដែលមានរោគរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃនឹងវិវឌ្ឍទៅជាបញ្ហាថ្លើមធ្ងន់ធ្ងរដល់ថ្នាក់កើតមហារីកទៀតផង ប៉ុន្តែអាចព្យាបាល និងតាមដានជំងឺនៅពេលរកឃើញក្នុងដំណាក់ដំបូងៗ។

## តើរោគរលាកថ្លើមប្រភេទ B ចម្លងតាមរបៀបណា?

រោគរលាកថ្លើមប្រភេទ B ចម្លងពីមនុស្សទៅមនុស្សតាមរយៈការប៉ះពាល់ជាមួយនឹងឈាម ឬសារធាតុរាវនៃរាងកាយដែលមានមេរោគ។ វាអាចចម្លងតាមរយៈ៖

- មនុស្សមានផ្ទៃពោះទៅទារកអំឡុងពេលសម្រាលកូន
- ការប៉ះពាល់ឈាមរបស់មនុស្សដែលមានផ្ទុករោគរលាកថ្លើមប្រភេទ B
- ការប្រើសម្ភារៈថែទាំផ្ទាល់ខ្លួនដូចជា ច្រាសដុសធ្មេញ ផ្លែឡាម កន្ត្រៃកាត់ក្រចក ឬឧបករណ៍វេជ្ជសាស្ត្រ (ដូចជាប្រដាប់វាស់ជាតិស្ករជាដើម) រួមគ្នាជាមួយមនុស្សដែលមានផ្ទុករោគរលាកថ្លើមប្រភេទ B
- ការប៉ះពាល់ផ្លូវភេទ
- ការប្រើម្ជុល ស៊ីរ៉ាំង ឬឧបករណ៍រៀបចំថ្នាំរួមគ្នា

## រោគរលាកថ្លើមប្រភេទ B មិនចម្លងតាមរយៈ៖

- ការប្រើសម្ភារៈញ៉ាំអាហារ ឬញ៉ាំអាហាររួមគ្នា
- ការប៉ះពាល់គ្នាជាធម្មតាដូចជា ការអោប ថើប ឬកាន់ដៃគ្នា
- ទឹកឬខ្យល់

### សម្រាប់ព័ត៌មានបន្ថែម៖

**Centers for Disease Control and Prevention (CDC, មជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺ)**
www.cdc.gov/hepatitis/hbv/

Hep B Hub
doh.wa.gov/hepbhub

DOH 420-405 May 2022 Khmer

ដើម្បីស្នើសុំឯកសារនេះជាទម្រង់ផ្សេងទៀត សូមទូរសព្ទទៅលេខ 1-800-525-0127។ អតិថិជនស្តាប់មិនឮ ឬស្តាប់មិនសូវឮ សូមទូរសព្ទទៅលេខ 711 (Washington Relay) ឬផ្ញើអ៊ីមែលទៅ civil.rights@doh.wa.gov។

ប្រភព៖ Minnesota Department of Health, Hepatitis B



# រោគរលាកថ្លើមប្រភេទ B៖ អ្វីដែលអ្នកគ្រប់គ្នាគួរដឹង

Washington State Department of Health




## តើនរណាខ្លះគួរធ្វើតេស្ត?

វិធីតែមួយគត់ដើម្បីដឹងថាអ្នកមានផ្ទុករោគរលាកថ្លើមប្រភេទ B ឬអត់គឺត្រូវធ្វើតេស្ត។

- មនុស្សមានផ្ទៃពោះទាំងអស់គួរតែធ្វើតេស្តរកមើលរោគរលាកថ្លើមប្រភេទ B ជាប្រចាំ។ ប្រសិនបើមនុស្សដែលមានផ្ទៃពោះមានផ្ទុករោគរលាកថ្លើមប្រភេទ B នោះការចាក់វ៉ាក់សាំងទាន់ពេលវេលាអាចជួយបង្ការមិនឱ្យចម្លងមេរោគទៅទារកបាន។
- មនុស្សដែលរស់នៅជាមួយនរណាម្នាក់ដែលមានផ្ទុករោគរលាកថ្លើមប្រភេទ B។
- មនុស្សមានហានិភ័យខ្ពស់ដែលអាចនឹងកើតរោគរលាកថ្លើមប្រភេទ B។ ចំណុចនេះរួមមាន៖
  - មនុស្សដែលបានកើតក្នុងតំបន់ដែលមានការឆ្លងរោគរលាកថ្លើមប្រភេទ B ជាញឹកញាប់ ឬមានឪពុកម្ដាយដែលបានកើតនៅតំបន់ទាំងនោះ ដូចជានៅទ្វីបអាហ្វ្រិកឬអាស៊ីជាដើម។
  - មនុស្សដែលចាក់ថ្នាំ
  - បុរសដែលរួមភេទជាមួយបុរស

## តើនរណាខ្លះគួរចាក់វ៉ាក់សាំង?

Centers for Disease Control and Prevention (CDC) ណែនាំឱ្យចាក់វ៉ាក់សាំងរោគរលាកថ្លើមប្រភេទ B សម្រាប់មនុស្សភាគច្រើន រួមមាន៖

- ទារកគ្រប់រូប
- កុមារ និងមនុស្សពេញវ័យអាយុរហូតដល់ 59 ឆ្នាំដែលមិនបានចាក់វ៉ាក់សាំងគ្រប់រូប ដោយមិនគិតពីកត្តាហានិភ័យផ្សេងៗ
- មនុស្សពេញវ័យអាយុ 60 ឆ្នាំឡើងទៅដែលមានកត្តាហានិភ័យ៖
  - មនុស្សប្រឈមនឹងហានិភ័យដែលអាចកើតរោគដោយការប៉ះពាល់ផ្លូវភេទ
  - មនុស្សមានហានិភ័យដែលអាចឆ្លងរោគតាមការចាក់ថ្នាំតាមស្បែកឬភ្នែក/មាត់/ច្រមុះប៉ះពាល់ជាមួយនឹងឈាម
  - អ្នកធ្វើដំណើរទៅតំបន់ដែលរោគរលាកថ្លើមប្រភេទ B មានអត្រាឆ្លងមធ្យមឬខ្ពស់
  - មនុស្សដែលមានជំងឺថ្លើមរ៉ាំរ៉ៃ
  - មនុស្សដែលបានឆ្លងវីរុស HIV
  - មនុស្សដែលជាប់ពន្ធនាគារ
  - មនុស្សផ្សេងទៀតទាំងអស់ដែលស្វែងរកការការពារពីរោគរលាកថ្លើមប្រភេទ B



**មនុស្សប្រមាណ 296 លាននាក់**
កំពុងរស់នៅដោយមានផ្ទុករោគរលាកថ្លើមប្រភេទ B នៅទូទាំងពិភពលោក ប៉ុន្តែមនុស្សជាច្រើនមិនដឹងខ្លួនថាបានឆ្លងមេរោគ ដោយសារពួកគេមិនមានអារម្មណ៍ ឬមើលទៅដូចជាមានជំងឺទេ។



## តើវ៉ាក់សាំងមានសុវត្ថិភាពដែរទេ?

វ៉ាក់សាំងរោគរលាកថ្លើមប្រភេទ B មានប្រសិទ្ធភាព និងសុវត្ថិភាព។ វ៉ាក់សាំងនេះត្រូវបានប្រើនៅសហរដ្ឋអាមេរិកតាំងពីឆ្នាំ 1982។

វ៉ាក់សាំងរោគរលាកថ្លើមប្រភេទ B ជាងមួយពាន់លានដូសត្រូវបានចាក់នៅទូទាំងពិភពលោក។

ប្រតិកម្មដែលកើតមានជាញឹកញាប់បំផុតដោយសារវ៉ាក់សាំងនេះគឺ គ្រុនក្តៅពីកម្រិតស្រាលទៅមធ្យម និងឈឺត្រង់កន្លែងដែលបានចាក់។ ផលប៉ះពាល់ទាំងនេះអាចមានរយៈពេល 1-2 ថ្ងៃ។

## តើខ្ញុំអាចចាក់វ៉ាក់សាំងរោគរលាកថ្លើមប្រភេទ B នៅឯណា?

សូមពិភាក្សាជាមួយឱសថស្ថាន អ្នកផ្តល់សេវាថែទាំសុខភាព ឬក្រសួងសុខាភិបាលក្នុងតំបន់របស់អ្នកអំពីការចាក់វ៉ាក់សាំង។ គ្លីនិកមួយចំនួនផ្តល់ការចាក់វ៉ាក់សាំងរោគរលាកថ្លើមប្រភេទ B ក្នុងតម្លៃទាប ឬឥតគិតថ្លៃ។

ការធានារ៉ាប់រងសុខភាពអាចទូទាត់ថ្លៃវ៉ាក់សាំងសម្រាប់មនុស្សគ្រប់រូបដែលមានអាយុរហូតដល់ 59 ឆ្នាំ និងមនុស្សអាយុចាប់ពី 60 ឆ្នាំឡើងទៅដែលមានកត្តាហានិភ័យ។

ប្រសិនបើអ្នកសម្រាលកូន នោះទារករបស់អ្នកអាចចាក់វ៉ាក់សាំងរោគរលាកថ្លើមប្រភេទ B នៅមន្ទីរពេទ្យមុនពេលអ្នកចាកចេញ។ វ៉ាក់សាំងមានផ្តល់ជូនទារកទើបនឹងកើតដោយឥតគិតថ្លៃ។